# សេចក្តីថ្លែងការណ៍រួមរបស់
# អង្គការសង្គមស៊ីវិលអំពី ការព្រួយបារម្ភលើ នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង( PNPCA )ចំពោះទំនប់វារីអគ្គិសនី ដន សាហុង

សម្ព័ន្ធទន្លេកម្ពុជា (RCC) ជាមួយនឹងក្រុមអភិរក្សអន្តរជាតិដូចជា អង្គការអភិរក្សអន្តរជាតិ (CI) អង្គការអុកស្វាម និងមូលនិធិសកលសម្រាប់ធម្មជាតិ (WWF) ព្រមទាំងអង្គការជាតិ និងអន្តរជាតិចំនួន ១៥ ទៀត សូមលើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំងរបស់យើងលើនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និង កិច្ចព្រមព្រៀង (PNPCA) សម្រាប់គម្រោងទំនប់វារីអគ្គិសនី ដនសាហុង ( DSHPP )។

សេចក្តីថ្លែងការណ៍អំពីការព្រួយបារម្ភនេះ ត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ អំពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ដែលបានរៀបចំឡើងកាលពី ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ ភ្នំពេញ នៅប្រទេសកម្ពុជា។

## សាវតា

"ការពិគ្រោះយោបល់ជាមុន" គឺជាសមាសភាគសំខាន់មួយសម្រាប់ដំណើរការនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងរបស់គណៈកម្មការទន្លេមេគង្គ (MRC) ដែលបង្កើតឡើងជាមូលដ្ឋានសម្រាប់កិច្ចព្រមព្រៀងដងទន្លេមេគង្គឆ្នាំ១៩៩៥ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ កិច្ចព្រមព្រៀងនេះគឺដើម្បីគ្រប់គ្រងការប្រើប្រាស់ដែលបានបែងចែកឆ្លងកាត់ព្រំដែនទន្លេមេគង្គ។ ជាផ្នែកមួយនៃកិច្ចព្រម ព្រៀងនេះ គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលបង្កផលប៉ះពាល់ឆ្លងព្រំដែនលើធនធានទឹក ដែលបានគ្រោងនៅលើទន្លេមេត្រូវតែឆ្លងកាត់ដំណើរការរបស់ PNPCA ជាមុនរាល់ការសាងសង់ទាំងអស់។

ទោះបីយ៉ាងណាក៏ដោយ ដំណើរការនេះបានបរាជ័យចាប់តាំងពីប្រទេសឡាវបានចាប់ផ្តើមការសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរីនៅក្នុងឆ្នាំ ២០១២ ទោះបីជាមានមតិតបច្បាស់លាស់ ហើយខ្លាំង ពីរដ្ឋាភិបាលគណៈកម្មការទន្លេមេគង្គដែលប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គិសនីបន្ទាប់ពីការពិគ្រោះយោបល់ក្តី។ ចាប់តាំងពីពេលនោះមក និយមន័យច្បាស់លាស់ និងកិច្ចព្រមព្រៀងស្តីពីដំណើរការគណៈកម្មការទន្លេមេគង្គ ត្រូវបានបង្កើតឡើងវិញដោយមិនបានទទួលជោគជោគជ័យនោះទេ ហើយនីតិវិធីសម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង នៅតែមានបញ្ហាមិនចុះសម្រុងគ្នា។

## បញ្ហាធ្ងន់ធ្ងរលើដំណើរការ PNPCA សម្រាប់គម្រោងទំនប់វារីអគ្គិសនីដនសាហុង

ក្នុងនាមជាសមាជិកអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល បានព្រមព្រៀងចែករំលែកនូវការព្រួយបារម្ភយ៉ាងខ្លាំងលើទំនប់វារីអគ្គិសនី ដនសាហុង ដូចខាងក្រោម៖

១. ផលប៉ះពាល់អវិជ្ជមានពីគម្រោងទំនប់វារីអគ្គិសនី ដនសាហុងចំពោះសហគមន៍ក្នុងប្រទេសកម្ពុជា ជាពិសេស ប៉ះពាល់ទៅដល់បរិស្ថាន និងជីវៈចម្រុះ ហើយយើងមិនមានការជឿជាក់ថា គោលការណ៍ បង្ការត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាពនោះទេ។

២. កង្វះខាតនៃការសិក្សាស្រាវជ្រាវឯករាជ្យផ្នែកវិទ្យាសាស្ត្រនៅមូលដ្ឋាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឆ្លងដែនលើទំនប់វារីអគ្គិសនី ដនសាហុង។ តម្រូវការបន្ទាន់មួយចាំបាច់ត្រូវសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយអ្នកស្រាវជ្រាវជំនាញឯករាជ្យលើការប៉ះពាល់ឆ្លងដែនដោយទំនប់វារីអគ្គិសនី ដន

សាហុង ដើម្បីផ្ទៀងផ្ទាត់ជាមួយការវាយតម្លៃហេតុប៉ះពាល់បរិស្ថានតែមួយគត់ដែលត្រូវបានប្រើប្រាស់ដោយម្ចាស់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ក្រុមហ៊ុន Mega First Corporation Berhad ( MFCB ) ។

៣. វិធានការកាត់បន្ថយអំពីការផ្លាស់ទីរបស់ត្រីដែលត្រូវបានសិក្សាដោយអ្នកស្រាវជ្រាវអន្តរជាតិជំនាញខាងជលផល ដែលបានស្នើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល បានបង្ហាញថាការសិក្សាEIA របស់ក្រុមហ៊ុនគឺមិនស្របតាមស្តង់ដារអន្តរជាតិនោះទេហើយការដោះស្រាយផ្លូវវាងរបស់ត្រីមិនត្រូវបានបង្ហាញ។[1]

៤. វិធីសាស្ត្រកាត់បន្ថយផលប៉ះពាល់ដែលក្រុមហ៊ុន Mega First បានរៀបចំមិនបានធ្វើសាកល្បង និងដំណើរការ។ ដូចជាការបំលាស់ទីរបស់ត្រីដូចជាបានលើកឡើងប៉ុន្តែមិនមានបញ្ជាក់ពីករណីដែលធ្វើបានជោគជ័យ ឬបង្ហាញថាវាអាចដំណើរការបានក្នុងបរិបទទំនប់ដនសាហុង។ នេះគួរត្រូវជាតម្រូវការក្នុងកិច្ចពិគ្រោះយោបល់។

៥. ទំហំ និងលទ្ធផលរំពឹងទុកនៃដំណើរការកិច្ចពិគ្រោះយោបល់មិនមានទំនាក់ទំនងច្បាស់លាស់។ វាមិនច្បាស់ពីអ្វីជាគោលបំណងនៃកិច្ចពិគ្រោះយោបល់និងអ្វីដែលយើងរំពឹងទុកលើលទ្ធផលប្រសិនជាយើងចូលរួម។

៦. មិនមានតំណាងម្ចាស់គម្រោងចូលរួម នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិដើម្បីធ្វើបទបង្ហាញលំអិតអំពីគម្រោងទេ។ ទង្វើនេះគឺជាការគេចវេះពីការទទួលខុសត្រូវក្នុងការធានាឲ្យអ្នកចូលរួមយល់ឲ្យបានច្បាស់អំពីគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ និងការសិក្សាផ្សេងៗទៀត។

៧. កិច្ចពិគ្រោះយោបល់បានបរាជ័យក្នុងការបង្ហាញអ្វីដែលមានចំពោះជម្រើសនិរន្តរភាពជាច្រើនដូចជាគម្រោងបង្វែទឹកពីព្រែកឋាកូ ដែលមានកំលាំងថាមពលអគ្គិសនីដូចគ្នាជាជម្រើសថោកជាង និងផលប៉ះពាល់លើត្រី និងផ្សោតតិចជាងក្នុងខណៈដែលមានសក្តានុពលសម្រាប់នាវាចរនិងសម្របសម្រួលការដឹកជញ្ជូនរវាងប្រទេសនីមួយៗ

៨. ម្តងហើយម្តងទៀត រដ្ឋាភិបាលឡាវ និងក្រុមហ៊ុន Mega First បានទទូចជាសាធារណៈថា គម្រោងដនសាហុង នឹងត្រូវសាងសង់ដោយមិនគិតពីលទ្ធផលនៃការពិគ្រោះយោបល់នោះទេ។ ការសាងសង់បឋមនៃទំនប់វារីអគ្គិសនីនៅតែមិនព្រមបញ្ឈប់ខណៈពេលដែលដំណើរការ PNPCA នៅតែកំពុងអនុវត្តបន្ត។ បើមិនមានការដោះស្រាយពីប្រទេសឡាវ និងក្រុមហ៊ុន Mega First អំពីផលប៉ះពាល់ទាំងនោះទេនោះដំណើរការ PNPCA ដែលកំពុងបន្តគឺមិនមានន័យនោះទេ។

៩. ការពិគ្រោះយោបល់ថ្នាក់ខេត្តក្នុងប្រទេសកម្ពុជា[2] បានទទួលបរាជ័យជាច្រើនដងលើគោលបំណងចំបងរបស់ខ្លួនស្តីពីការចែកចាយព័ត៌មានអោយបានច្បាស់លាស់ពីទំនប់វារីអគ្គិសនីដន សាហុង នេះទៅដល់អ្នកចូល រួម ព្រមទាំងជួយអ្នកចូលរួមឲ្យស្វែងយល់ពីគម្រោង ផលប៉ះពាល់ និងការពិភាក្សាឲ្យបានពេញលេញដែលចំណុចភាគច្រើនគឺសុទ្ធតែជាប្រើបច្ចេកទេស ហើយស្មុគស្មាញ។ ឧទាហរណ៍ ដូចជា ឯកសារបោះពុម្ពដែលត្រូវចែកជូនដល់អ្នកចូលរួមភាគច្រើនជាភាសាអង់គ្លេស។ បទបង្ហាញទាំងពីរ និងឯកសារបោះពុម្ពមានពាក្យបច្ចេកទេស និងវាក្យស័ព្ទជាច្រើនដែលពិបាកក្នុងការពន្យល់ទៅដល់អ្នកចូលរួម។ អ្នក

---

1 "SUMMARY OF SCIENTIFIC REVIEWS FROM THREE INTERNATIONAL FISH PASSAGE EXPERTS ON THE DON SAHONG DAM EIA AND TECHNICAL REPORTS RELATED TO PROJECT DESIGN AND MITIGATION MEASURES, Feb 2014. Download at http://awsassets.panda.org/downloads/wwf_scientific_review_by_3_fish_passage_experts_finalrevised12mar.pdf

2 Sub-national level consultation workshops were held separately in two provinces - Stung Treng on 16-18 Oct and in Battambang on 30-31 Oct, 2014.

ចូលរួមផ្តល់មតិតបថា ពួកគេមិនយល់នូវការធ្វើបទបង្ហាញទាំងស្រុង។ ការធ្វើបទបង្ហាញប្រញាប់ប្រញាល់ពេក។ មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អ្នកចូលរួមផ្តល់មតិតប/ឬសំណួរដើម្បីបញ្ជាក់ពីចំណុចដែលពួកគេមិនយល់។ កត្តាទាំងនេះហើយដែលធ្វើឲ្យពួកគេកាន់តែមានការភាន់ច្រឡំកាត់តែជ្រៅទៅដោយសារតែខ្វះការបញ្ជាក់ឲ្យបានច្បាស់។

១០. ភាពជាតំណាង "អ្នកពាក់ព័ន្ធផ្សេងៗ"មិនមែនជាតំណាងដ៏ពិតប្រាកដទេ។ដំណើរការនេះផ្តល់ភាពពិបាកដល់សហគមន៍ដោយមិនបានផ្តល់ព័ត៌មាននិងពេលវេលាគ្រប់គ្រាន់សម្រាប់សហគមន៍ ដែលបានចូលរួមពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍របស់ពួកគាត់។សហគមន៍ដែលបានចូលរួមនៅក្នុងការពិគ្រោះយោបល់មិនអាចផ្តល់ភាពជាតំណាងដល់សហគមន៍ទូទាំងខេត្តបានទេ។ក្នុងចំណោមអ្នកចូលរួមដែលបានអញ្ជើញ៨០នាក់ មានត្រឹមតែសហគមន៍៦នាក់ មកពីខេត្តចំនួន៦ និងអង្គការចំនួន៦ ក្នុងចំណោមអ្នកចូលរួម៨០នាក់។ ចំនួនដ៏តិចតួចរបស់សហគមន៍ និងអង្គការនេះត្រូវបានអ្នករៀបចំចាត់ទុកថាជាអ្នកតំណាងសង្គមស៊ីវិលតាមដងទន្លេមេគង្គក្រោម។

១១. អ្នករៀបចំមិនបានផ្តល់ពេលវេលា និងធនធានគ្រប់គ្រាន់ដល់អ្នកចូលរួមក្នុងដំណើរការពិគ្រោះយោបល់ក្នុងសិក្ខាសាលា ដូចច្នេះអ្នកចូលរួមមិនបានរៀបចំធាតុចូល និងផ្តល់យោបល់ដែលមានលក្ខណៈពេញលេញ និងមានអត្ថន័យនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត។ ឯកសារបានផ្ញើរឲ្យអ្នកចូលរួមត្រឹមតែ៣ថ្ងៃប៉ុណ្ណោះមុនពេលសិក្ខាសាលា ដែលមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គការ និងសហគមន៍ក្នុងការពិគ្រោះយោបល់ និងទទួលយកធាតុចូលពីសមាជិករបស់ពួកគេ។ អ្នកតំណាងដែលមានអញ្ជើញ មិនត្រូវបានផ្តល់ធនធាន និងជំនួយក្នុងការចែករំលែកព័ត៌មានមុនពេលសិក្ខាសាលាទេ។

## **អនុសាសន៍របស់អង្គការសង្គមស៊ីវិល**

១. ស្នើសុំបញ្ឈប់សាងសង់ទំនប់ដនសាហុងជាបន្ទាន់ រួមទាំងការសាងសង់ផ្លូវ និងស្ពានជំហានដំបូងរហូតដល់ឯកសារគម្រោង និងការវាយតម្លៃផ្សេងៗពីផលប៉ះពាល់បានទទួលយកពីក្តីបារម្ភរបស់អ្នកពាក់ព័ន្ធរួមមានរដ្ឋាភិបាលគណៈកម្មការទន្លេមេគង្គ សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាននៃតំបន់ទន្លេមេគង្គក្រោម។

២. ធ្វើឲ្យប្រាកដថារាល់ឯកសារនានារបស់ទំនប់ដនសាហុងត្រូវបានចែករំលែកទាំងក្នុងការសរសេរ និងនិយាយជាភាសាជាតិនៃប្រទេសដែលពិគ្រោះយោបល់ និងផ្តល់ជូនឯកសារជាមុន ៣០ថ្ងៃ។

៣. ធ្វើការសិក្សាផ្សេងពីគ្នាពី EIA ផលប៉ះពាល់ឆ្លងដែន និងឯករាជ្យ ជាមួយនឹងសិក្សាលំអិតពីផលប៉ះពាល់ឆ្លងដែនរបស់ត្រី និងផ្សោតនៅក្រោមទំនប់។

៤. ទទួលយកជម្រើសផ្តួចផ្តើមដែលមានស្រាប់ដូចជាគម្រោងបង្វែទឹកពីព្រែកឞាកូ ដែលមានផលប៉ះពាល់តិចជាងទំនប់ដនសាហុង ហើយមានកំលាំងថាមពលអគ្គិសនីដូចគ្នា។

៥. គួរបង្កើនចំនួនអ្នកតំណាងអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានក្នុងសិក្ខាសាលាពិគ្រោះយោបល់។

៦. សម្របសម្រួលការពិគ្រោះយោបល់ជាសាធារណៈដោយពេញលេញជាមុនក្នុង នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ឧទាហរណ៍ក្នុងប្រទេសកម្ពុជាគួរមានកិច្ចពិគ្រោះយោបល់នៅថ្នាក់ឃុំជាមួយសហគមន៍ដែលរងផលប៉ះពាល់ផ្ទាល់ ជូនដំណឹងពួកគាត់ពីសក្តានុផលរបស់ទំនប់ និងប្រមូលយកការផ្តល់ព័ត៌មានត្រលប់របស់ពួកគាត់។

៧. សម្របសម្រួលការពិគ្រោះយោបល់ជាសាធារណៈដោយពេញលេញជាមុនក្នុង នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ឧទាហរណ៍ក្នុងប្រទេសកម្ពុជាគួរមានកិច្ចពិគ្រោះយោបល់នៅថ្នាក់ឃុំជាមួយសហគមន៍ដែលរងផលប៉ះពាល់ផ្ទាល់ ជូនដំណឹងពួកគាត់ពីសក្តានុផលរបស់ទំនប់ និងប្រមូលយកការផ្តល់ព័ត៌មានត្រលប់របស់ពួកគាត់។

៨. ការព្រួយបារម្ភ និងការផ្តល់អនុសាសន៍របស់សង្គមស៊ីវិល និងសហគមន៍គួរពិចារណានូវគ្រប់ដំណើរការពិគ្រោះយោបល់ និងចែករំលែករបាយការណ៍ផ្លូវការទៅអ្នកចូលរួមដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ចុងក្រោយ។កំណត់ត្រាអំពីការព្រួយបារម្ភ និងមតិយោបល់ត្រូវតែ ពិចារណានៅគ្រប់ដំណើរការធ្វើសេចក្តីសម្រេចចិត្តលើគម្រោងទំនប់វារីអគ្គិសនីដន សាហុង។

៩. គណៈកម្មការទន្លេមេគង្គ និងរដ្ឋាភិបាលដែលជាសមាជិកគួរតែកំណត់ឲ្យបានច្បាស់លាស់នូវគោលបំណង និងលក្ខណៈវិនិច្ឆ័យរបស់នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង(PNPCA) មុនពេលការចាប់ផ្តើមដំណើរការពិគ្រោះយោបល់។

១០. ទំនាក់ទំនងជាមួយអ្នកចូលរួមអំពីដំណើរការឲ្យបានច្បាស់លាស់ផ្តល់ពេលវេលាគ្រប់គ្រាន់ជាមុនសម្រាប់ការត្រៀមលក្ខណៈចូលរួមពិគ្រោះយោបល់ បង្ហាញឲ្យបានច្បាស់នូវតួនាទីរបស់អ្នកចូលរួម និងកម្រិតនៃការចូលរួមរបស់ពួកគាត់ លទ្ធផលរំពឹងទុកពីការពិគ្រោះយោល់ និងបញ្ជាក់ឲ្យបានច្បាស់នូវពេលវេលានៃដំណាក់កាលនីមួយៗ និងមានប្រព័ន្ធតាមដានប្រកបដោយតម្លាភាព។

១១. ដំណើរការពិគ្រោះយោបល់មិនគួរធ្វើសេចក្តីសន្និដ្ឋានរហូតដល់មានការសិក្សាអំពីផលប៉ះពាល់ឆ្លងដែន និងផលប៉ះពាល់ស៊ីជម្រៅផ្សេងទៀតត្រូវមានបញ្ចប់។

១២. ប្រទេសខ្សែទឹកខាងក្រោមទន្លេមេគង្គទាំងអស់ត្រូវមានការឯកភាព និងមានការយល់ឃើញដូចគ្នាអំពីនិតិវិធីក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ហើយត្រូវតែគោរពឲ្យបានខ្ជាប់ខ្ជួនទៅលើការអនុវត្តរបស់ពួកគេ។

**សម្ព័ន្ធទន្លេកម្ពុជា និង អង្គការជាតិ និង អន្តរជាតិ ដែលគាំទ្រលើសេចក្តីថ្លែងការណ៍រួមនេះមាន ៖**

- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា(NGOF)
- បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង(3SPN)
- សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល(FACT)
- សមាគមថែរក្សាបរិស្ថាន និងវប្បធម៌(CEPA)
- អង្គការភូមិខ្ញុំ(MVi)
- អង្គការអភិរក្សអន្តរជាតិ (CI)
- មូលនិធិសកលសម្រាប់ធម្មជាតិ (WWF)
- អុកស្វាម (Oxfam)
- អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
- អង្គការថែរក្សាជនជាតិដើមភាគតិចកម្ពុជា (SVC)
- អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED)
- អង្គការអាដហុក (ADHOC)
- សមាគមន៍កសិករខ្មែរ (KFA)
- អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន (NRD)
- អង្គការពន្លកខ្មែរ (PKH)

- ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)
- មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍(CLEC)
- អង្គការម្លប់ព្រហ្មវិហារធម៌ (MPC)
- អង្គការសហប្រតិបត្តិការបរិស្ថាន និង ទេសចរណ៍ (CETO)
- អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam)
- អេកូសានកម្ពុជា (EcoSun Cambodia)
- អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍(AFD)
- អង្គការហេនរេចបូល ស្ទីហ្វទង់ កម្ពុជា (HBS)

**ចម្លងជូន៖**

- ក្រសួងធនធានទឹក និង ឧតុនិយម
- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- គណៈកម្មាធិការជាតិទន្លេមេគង្គឡាវ
- គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម
- គណៈកម្មាធិការជាតិទន្លេមេគង្គថៃ
- គណៈកម្មការទន្លេមេគង្គ
- រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
- ក្រសួងរ៉ែ និង ថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការពារជាតិ
- ក្រសួងកិច្ចការនារី
- ក្រសួងការបរទេស និង កិច្ចសហប្រតិបត្តិការអន្តរជាតិ
- ដៃគូអភិវឌ្ឍន៍
- អ្នកសារព័ត៌មានជាតិ និង អន្តរជាតិ

**សម្រាប់ព័ត៌មានលំអិត សូមទំនាក់ទំនង ៖**


- បណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

លេខទូរស័ព្ទ ៖ ០១២ ៧៩៣ ៤៨៩ អ៊ីម៉ែល ៖ vannara@ngoforum.org.kh

- លោក ឈិត សំអាត នាយកអង្គការប្រចាំប្រទេស មូលនិធិសកលសម្រាប់ធម្មជាតិ

លេខទូរស័ព្ទ ៖ ០១២ ៩២៨ ៥៨៥ អ៊ីម៉ែល ៖ SamAth.Chhith@wwfgreatermekong.org